# ការសន្ទនាសហគមន៍
# ឆ្នាំ ២០១០

តើយើងអាចរួមគ្នាធ្វើការរបៀបណាដើម្បីលើកកំពស់
សុវត្ថិភាព និងសុខដុមរមនាក្នុងសង្គម?

VBNK
An institute to serve facilitators of development

# របាយការណ៍សន្ទនាសហគមន៍វប៊ីអិនខេ

## តើយើងអាចរួមគ្នាធ្វើការរបៀបណាដើម្បីលើកកំពស់សុវត្ថិភាព និងសុខដុមរមនាក្នុងសង្គម?

### ប្រវត្ត

ជារៀងរាល់ឆ្នាំអង្គការ *វប៊ីអិនខេ* តែងតែរៀបចំការសន្ទនាសហគមន៍មួយ ដែលអញ្ជើញសមាជិកសហគមន៍តាមក្រុមមានអាយុ និងបទពិសោធន៍ជីវិតខុសៗគ្នាដូចជា អ្នកអភិវឌ្ឍន៍សហគមន៍ រដ្ឋអំណាចមូលដ្ឋាន និងបុគ្គលិក មន្ត្រីរដ្ឋាភិបាល មកកំណត់ និងពិភាក្សាទៅលើរឿងរ៉ាវក្នុងការអភិវឌ្ឍសង្គមសំខាន់ៗ។

កាលពីឆ្នាំកន្លងមក វេទិកានៃការសន្ទនាសហគមន៍របស់ *វប៊ីអិនខេ* បានផ្តោតទៅលើការផ្លាស់ប្តូរសង្គមចំបងៗ ដែលកើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងដប់ឆ្នាំចុងក្រោយ ដែលការរីកលូតលាស់បានកើនឡើងខ្ពស់ (លើសពី១០%)។ សិក្ខាកាមបានពិចារណានូវសំណួរដូចតទៅនេះ៖ តើការកើនឡើងនេះបានធ្វើអោយមានភាពខុសប្លែកគ្នាដែរឬទេ? ហើយប្រសិនបើមានភាពខុសប្លែកគ្នា តើខុសគ្នារបៀបណា? ពួកគេបានទាញចេញនូវសេចក្តីសន្និដ្ឋានដូចតទៅនេះ៖ ទី១ ឱកាសដែលប្រជាពលរដ្ឋនៅតាមសហគមន៍បានចូលរួមនៅក្នុងវេទិកាស្តីពី ការអភិឌ្ឍនានាមានការកើនឡើង ក៏ប៉ុន្តែសហគមន៍នៅតែមានអារម្មណ៍ថា ការអភិវឌ្ឍគឺជាអ្វីៗដែលគេធ្វើអោយពួកគាត់។ ទី២ ការពិភាក្សាអំពីបញ្ហាយេនឌ័រមានការកើនឡើង ក៏ប៉ុន្តែវិសមភាពយេនឌ័រនៅតែកើតមាន ។ ទី៣ មានតំរូវការអោយលោកគ្រូអ្នកគ្រូ និងអ្នកផ្តល់សេវាសុខភាពនានា មានការតាំងចិត្តខ្ពស់ និងមានការទទួលខុសត្រូវជាងមុន។ ទី៤ ទំនៀមទំលាប់ ប្រពៃណី និងសីលធម៌សង្គមនៅតែជារនាំងចំពោះស្ត្រី និងបុរសចូលរួមក្នុងដំណើរការអភិវឌ្ឍ ។



គោលដៅនៃការសន្ទនាសហគមន៍ឆ្នាំ ២០១០ នេះ គឺមើលឡើងវិញទៅលើសេចក្តីសន្និដ្ឋានទាំងនេះដើម្បីស្វែងយល់តាមរយៈសំណួរមួយចំនួនរួមមាន៖ តើបញ្ហាទាំងនេះនៅតែកើតមានចំពោះសហគមន៍មែនដែរឬទេ? តើយុវវ័យយល់ពីតម្រូវការ និងការព្រួយបារម្ភរបស់មនុស្សវ័យចំណាស់ដែរឬទេ? តើមនុស្សវ័យចាស់យល់បានពេញលេញនូវសេចក្តីប្រាថ្នា និងការព្រួយបារម្ភរបស់យុវវ័យដែរឬទេ? ថាតើអ្នកអភិវឌ្ឍសហគមន៍ស្តាប់យោបល់របស់សហគមន៍ដែលគេធ្វើការជាមួយបានកំរិតណា? តើមានអ្វីដែលជាឧបសគ្គសំរាប់សមាជិកសហគមន៍ក្នុងការចូលរួមវេទិកានានា? ហើយតើយើងអាចធ្វើការជាមួយគ្នាដើម្បីជំរុញអោយមានសុវត្ថិភាព និងសុខដុមរមនាក្នុងសង្គមដោយរបៀបណា? យើងបានជ្រើសរើស និងផ្តោតទៅលើសុវត្ថិ-ភាព និងភាពសុខដុមរមនាព្រោះថានៅសន្និសីទលើកមុនៗ សិក្ខាកាមបានលើកប្រធានបទទាំងពីរនេះឡើងជាញឹកញាប់។ ដូចនេះយើងចង់ស្វែងយល់ឲ្យបានច្បាស់ពីកត្តាជំរុញនៅពីក្រោយការព្រួយបារម្ភទាំងនោះ។

ការសន្ទនាបានរៀបចំឡើងរយៈពេលពីរថ្ងៃកន្លះ (ចាប់ពីថ្ងៃទី ២៩ មិថុនា រហូតដល់ថ្ងៃទី ០១ ខែកក្កដា ២០១០) នៅខេត្តព្រះសីហនុ ។ មានសិក្ខាកាមចូលរួមចំនួន ៩១នាក់ (ស្ត្រី ៤៦នាក់ និង បុរស ៤៥នាក់) ដែលមានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៦៣ឆ្នាំ។ ជារួមមានសមាជិកសហគមន៍ចំនួន ៤១នាក់ បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលដែលមកពីអង្គការចំនួន២៣ផ្សេងៗគ្នា ចំនួន៣៥នាក់ និងមន្ត្រីរដ្ឋាភិបាលមូលដ្ឋានចំនួន ១៥នាក់ មកពីខេត្ត-ក្រុងចំនួនប្រាំបី មានដូចជា កំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល តាកែវ កំពត កែប កោះកុង ព្រះសីហនុ និងភ្នំពេញ។

# លំហូរនៃសន្និសីទ

ឯកឧត្តម **ស៊ុន សុខន** អភិបាលខេត្តរងខេត្តព្រះសីហនុ បានអញ្ជើញចូលរួមបើកសន្និសីទ។ ក្នុងពិធីប្រារព្ធបើកសន្និសីទនេះ ឯកឧត្តម បានបង្ហាញនូវការគាំទ្រចំពោះសន្និសីទថា បាននាំមនុស្សមានបទពិសោធន៍ផ្សេងគ្នា មកជជែកគ្នាអំពីរបៀបដែលជំរុញអោយសង្គមកម្ពុជាមានសុវត្ថិភាព និងសុខដុមរមនាប្រសើរឡើង។ លោកបានរំពឹង ថាសន្និសីទនេះនឹងបង្កើនការយល់ដឹង ផ្តល់ជំនាញឲ្យសិក្ខាកាម ចេះបន្តការសន្ទនា និងចូលរួមឆ្លើយតបទៅនឹងឧបសគ្គប្រឈមនានាក្នុងប្រទេស។

ក្នុងរយៈពេលពីរថ្ងៃកន្លះ ជាដំបូងសិក្ខាកាមពិភាក្សាតាមវ័យខុសៗគ្នា (យុវវ័យ វ័យកណ្តាល និងសមាជិកសហគមន៍វ័យចំណាស់ រួមមាន បុគ្គលិករដ្ឋាភិបាល និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល) ដើម្បីធ្វើការឆ្លុះបញ្ចាំង និងទាញចេញនូវការរៀនសូត្រពីព្រឹត្តិការណ៍នានាដែលមានឥទ្ធិពលទៅដល់សង្គមកម្ពុជា ក្នុងអំឡុងពេលមួយទសវត្សរ៍ចុងក្រោយ និងដើម្បីបង្កើតទស្សនវិស័យតាមក្រុមសំរាប់ឆ្នាំ២០១៥។ រយៈពេលនេះបានផ្តល់ឱកាសដល់យុវវ័យ និងសមាជិកសហគមន៍វ័យចំណាស់បង្ហាញពីទស្សនៈ និងបង្កើតស្ថានភាពមួយដែលយើងត្រូវការរៀនស្តាប់តាមរបៀបថ្មី ដើម្បីទទួលយកអ្វីប្លែកៗ។ បន្ទាប់មកសិក្ខាកាមបានធ្វើការពិភាក្សាចម្រុះក្រុម ដើម្បីកំណត់រកឧបសគ្គរាំងស្ទះក្នុងការសំរេចទស្សនវិស័យ និងឆ្លើយនឹងសំណួរ ថាតើយើងនឹងធ្វើការរួមគ្នាដោយរបៀបណាដើម្បីជំនះឧបសគ្គទាំងនេះ។

ការសន្ទនាធ្វើឡើងតាមដំណើរការចូលរួមផ្សេងៗជាច្រើន ដើម្បីលើកទឹកចិត្តអោយមានការចែករំលែកជាលក្ខណៈបើកចំហរ និងមានសុវត្ថិភាព រួមមាន៖ ការពិភាក្សាតុកាហ្វេ ការពិភាក្សាក្រុមតូច ការលើកករណីសិក្សាតាមរយៈការគូររូបភាព និងការសំដែងតួ ព្រមទាំងការកត់ត្រាទុកជាលក្ខណៈបុគ្គល។



## ១. ការផ្លាស់ប្តូរជាលក្ខណៈវិជ្ជមាននៅក្នុងការអភិវឌ្ឍសង្គមកម្ពុជាក្នុងទសវត្សរ៍ចុងក្រោយ

សន្និសីទបានចាប់ផ្តើមឡើងដោយធ្វើការសួរទៅសិក្ខាកាមអោយពិចារណានូវសំណួរដូចជា៖ តើមានអ្វីផ្លាស់ប្តូរជាវិជ្ជមានចំបងៗក្នុងការអភិវឌ្ឍសង្គមកម្ពុជានៅក្នុងកំឡុងទសវត្សរ៍ចុងក្រោយនេះ?

ចំណុចគន្លឹះដែលរកឃើញចេញពីការពិភាក្សាមានដូចតទៅ៖

សហគមន៍សព្វថ្ងៃនេះមានឱកាសច្រើនក្នុងការបង្ហាញនូវតម្រូវការតាមរយៈវេទិកាផ្សេងៗ។

វេទិកាខ្លះបានកើតឡើងតាមរយៈដំណើរការវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជាដូចជាឱកាសក្នុងការផ្តល់យោបល់ និងផ្តល់ដំណឹងអំពីផែនការអភិវឌ្ឍឃុំ ។

មានកិច្ចសន្ទនាដ៏ល្អៗក្នុងចំណោមសហគមន៍ និងចែកចាយព័ត៌មានពីមូលដ្ឋានទៅរដ្ឋអំណាចថ្នាក់ខេត្ត។

ស្ថេរភាពនយោបាយមាននិរន្តរភាព។

នៅទសវត្សរ៍ចុងក្រោយមានការកត់សំគាល់ថា ជីវភាពរស់នៅជាទូទៅមានលក្ខណៈប្រសើរឡើង មានការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងមានការកែលំអរហេដ្ឋារចនាសម្ព័ន្ធ។

នៅក្នុងការពិភាក្សាក្រុមធំ អ្នកសម្របសម្រួលបានសង្កេតឃើញថា សិក្ខាកាមទាំងអស់បានធ្វើការគូសបញ្ជាក់ និងផ្តល់ជាឧទាហរណ៍ជាច្រើនដែលទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធ នៅពេលដែលលើកឡើងពីសមិទ្ធផលអភិវឌ្ឍន៍ប្រទេសកម្ពុជា ។ ពួកគេបានរំលេចឡើងតិចតួចពីការអភិវឌ្ឍសង្គម។ កិច្ចពិភាក្សាមានដំណើរការហូរហែទៅតាមតម្រូវការដោយពិចារណាទៅលើការអភិវឌ្ឍទាំងផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គម ហើយក្នុងនោះផងដែរផ្នែកអង្គការក្រៅរដ្ឋាភិបាលអាចដើរតួយ៉ាងសំខាន់ដើម្បីធ្វើឲ្យប្រាកដថា ការពិភាក្សាអំពីសេវាកម្មបំរើសង្គមត្រូវបានចាត់អាទិភាពឲ្យនៅជួរមុខគេ និងធនធានត្រូវបានបែងចែក ។

**២. តើរឿងរ៉ាវសំខាន់ៗ អ្វីខ្លះដែលយើងយកមកពិចារណា?**

នៅក្នុងការសន្ទនាបន្ទាប់ ដោយសំអាងលើការកំនត់បាននូវបញ្ហាសំខាន់ៗ ទាំងបួនពីការសន្ទនាសហគមន៍ឆ្នាំ ២០១០ នោះ អ្នកសម្របសម្រួលបានសួរថា៖ តើរឿងរ៉ាវទាំងនេះពាក់ពន្ធ័នឹងអ្នកដែរឬទេ? តើអ្នកយល់ថាមានអ្វីលើសពីនេះទៅទៀត?
រឿងរ៉ាវទាំងបួនដែលបានកំនត់ក្នុងឆ្នាំ ២០១០ មានដូចជា៖

- ទី១. ឱកាសដែលប្រជាពលរដ្ឋនៅតាមសហគមន៍បានចូលរួមនៅក្នុងវេទិកាស្តីពីការអភិវឌ្ឍនានាមានការកើនឡើង ក៏ប៉ុន្តែសហគមន៍នៅតែមានអារម្មណ៍ថាការអភិវឌ្ឍគឺជាអ្វីៗ ដែលគេធ្វើអោយពួកគាត់។
- ទី២. ការពិភាក្សាអំពីបញ្ហាយេនឌ័រមានការកើនឡើង ក៏ប៉ុន្តែវិសមភាពយេនឌ័រនៅតែកើតមាន ។
- ទី៣. មានតំរូវការអោយលោកគ្រូ អ្នកគ្រូ និងអ្នកផ្តល់សេវាសុខភាពនានា មានការតាំងចិត្តខ្ពស់ និងមានការទទួលខុសត្រូវជាងមុន។
- ទី៤. ទំនៀមទំលាប់ ប្រពៃណី និងសីលធម៌សង្គម នៅតែជារនាំងចំពោះស្ត្រី និងបុរស ក្នុងការចូលរួមក្នុងដំណើរការអភិវឌ្ឍ ។



បន្ទាប់ពីពិភាក្សា ក្រុមបានពិចារណាយ៉ាងល្អិតល្អន់ទៅលើរឿងរ៉ាវដូចតទៅ៖

- ☐ មានការកើនឡើងនូវឱកាសក្នុងការចូលរួមក្នុងវេទិការអភិវឌ្ឍនានា ជាពិសេសការចូលរួមក្នុងសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ។ នៅពេលមានការផ្សព្វផ្សាយច្បាប់ជាច្រើនដើម្បីគាំទ្រវិមជ្ឈការ និងវិសហមជ្ឈការ អភិបាលកិច្ចមូលដ្ឋាន ថ្នាក់ឃុំគួរមានលក្ខណៈ និងការអនុវត្តដូចៗគ្នា។ លើសពីនេះទៅទៀត ឋានានុក្រម និងទំនៀមទំលាប់ប្រពៃណី សង្គមនៅតែបន្តកំរិតការចូលរួមក្នុងដំណើរការអភិវឌ្ឍ ហើយសង្គមស៊ីវិលគួរតែបង្កើនទំនាក់ទំនងអោយកាន់តែប្រសើរឡើងជាមួយសមាជិកសហគមន៍ ស្តាប់យោបល់គេ និងឆ្លើយតបទៅនឹងការព្រួយបារម្ភរបស់ពួកគេ ។
- ☐ ការទទួលបានសេវាសង្គមមានការកើនឡើង។ ក៏ប៉ុន្តែចាំបាច់ត្រូវតែបញ្ជាក់បន្ថែមដើម្បីធានាថាសេវាកម្មបានឆ្លើយតប និងមានគណនេយ្យភាពចំពោះតម្រូវការរបស់សហគមន៍។ តម្រូវការនេះទាមទារអោយមានការខិតខំប្រឹងប្រែងមិនត្រឹមតែអ្នកផ្តល់សេវាកម្មប៉ុណ្ណោះទេ តែរួមទាំងសហគមន៍ និងអង្គការក្រៅរដ្ឋាភិបាលផងដែរ ។
- ☐ វិសមធម៌យេនឌ័រនៅតែមានដដែល និងត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតពីអ្នកទាំងអស់គ្នា។
- ☐ ខណៈដែលមានការរីកចំរើនផ្នែកហេដ្ឋារចនាសម្ព័ន្ធ គុណភាពហេដ្ឋារចនាសម្ព័ន្ធ (ជាពិសេសផ្លូវថ្នល់) នៅតែជាបញ្ហា។

### ៣. បង្កើតទស្សនវិស័យសំរាប់អនាគត

បន្ទាប់មក កិច្ចពិភាក្សាបានបង្កើតទស្សនវិស័យតាមក្រុមនីមួយៗសំរាប់ឆ្នាំ ២០១៥ ។ ក្នុងកំឡុងពេលរាយការណ៍វាបានស្តែងអោយឃើញថាទស្សនវិស័យផ្សេងៗគ្នាមានធាតុពីរគឺៈ



ធាតុទីមួយពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ដែលងាយមើលឃើញនោះមានដូចជា៖

- ☐ សេវាសង្គមដែលមានការទទួលខុសត្រូវ និងឆ្លើយតបទៅនឹងតម្រូវការសហគមន៍និងការរួមចំណែករបស់សហគមន៍យ៉ាងសកម្មទៅនឹងសេវាកម្មទាំងនេះ។
- ☐ តម្លាភាព និងគណនេយ្យភាពនៅក្នុងអភិបាលកិច្ចមូលដ្ឋាន។
- ☐ ទទួលខុសត្រូវក្នុងការគ្រប់គ្រងធនធានធម្មជាតិ។
- ☐ បង្កើនគុណភាពនៃលក្ខខណ្ឌរស់នៅ (វាស់វែងតាមភាពមានការងារធ្វើ ឬចំណូល និងសុវត្ថិភាពស្បៀង)។

ធាតុទីពីរគឺជាគុណតម្លៃបែបជាគោលការណ៍ (ឬជាអ្នកនាំផ្លូវ)។ គុណតម្លៃទាំងនេះរួមមានការនិយាយអំពីផលសំរេចបាននូវវប្បធម៌នៃការចែករំលែក ធ្វើការរួមគ្នា និងកិច្ចសហការណ៍ (ជាជាងការប្រគួតប្រជែង) គោរពទស្សនៈគ្នាទៅវិញទៅមក តម្លាភាព និងភាពស្មោះត្រង់។ គុណតម្លៃទាំងនេះវាជាបំណងប្រាថ្នាសម្រាប់ភាពសុខដុមរមនាក្នុងសង្គម។

## ៤. កត្តាជួយ និងកត្តារារាំង

បន្ទាប់មកទៀតសិក្ខាកាមបានពិភាក្សារកកត្តាជួយ និងកត្តារារាំងមិនអោយសំរេចទស្សនវិស័យរបស់ពួកគេ។ ការពិភាក្សារបស់ក្រុមមិនតម្រូវឲ្យយកចម្លើយច្រើននោះទេ ប៉ុន្តែក្រុមពិភាក្សាចាត់អាទិភាពកត្តារាំងស្ទះណាដែលសំខាន់ចំពោះក្រុមពួកគេ។ គោលបំណងពេលនេះគឺចង់លើកទឹកចិត្តឲ្យស្តាប់គ្នាទៅវិញទៅមក លើសពីនេះទៅទៀតក៏ចង់បង្ហាញថាជួនកាលការរៀបរាប់ច្រើននោះមិនជួយឲ្យក្រុមអាចយល់បានល្អទេ។ នៅពេលមានការឲ្យតម្លៃដូចៗគ្នាទៅលើគំនិតម្នាក់ៗ ហើយអ្វីៗមានសារៈសំខាន់ដូចគ្នានោះ វានាំឲ្យមានអាទិភាពច្រើនពេកក្នុងការទទួលយក។ ក្រុមនីមួយៗត្រូវបានសួរឲ្យមានការទទួលខុសត្រូវថា៖ តើយើងបានរួមចំណែកយ៉ាងដូចម្តេចខ្លះទៅនឹងបញ្ហានេះ? តាមមធ្យោបាយនេះ ពួកគេត្រូវបានលើកទឹកចិត្តឲ្យជៀសវាងការស្តីបន្ទោសអ្នកដទៃ ហើយអោយពួកគេមើលខ្លួនឯងជាមុនសិនមុននឹងមើលទៅអ្នកដទៃ។

មានការជជែកតវ៉ាគ្នាជាក្រុមយ៉ាងក្លៀវក្លាដើម្បីចាត់អាទិភាពជារួម។ ការសំដែងតួក្នុងសន្និសីទមានទម្រង់នាំអោយអ្នកសើចបានគិត និងមានការជជែកគ្នាបន្ថែមទៀតផង។ ឧទាហរណ៍ដូចជាតួអង្គសង្គមស៊ីវិលមានអារម្មណ៍ថា ពួកគេមិនមានដំណាងសមស្របទេនៅពេលគេចង់ធ្វើអ្វីមួយឲ្យមានភាពស្មើគ្នា។ ទោះជាយ៉ាងណាក្តីនៅចុងបញ្ចប់ក្រុមអាចបែងចែកឧបសគ្គទាំងខាងក្នុង (ជាឧបសគ្គរបស់យើងផ្ទាល់ខ្លួន) និងឧបសគ្គខាងក្រៅ ។

លទ្ធផលចេញពីការពិភាក្សានេះបង្ហាញដូចខាងក្រោម៖

| ឧបសគ្គខាងក្នុង | ឧបសគ្គខាងក្រៅ |
|---|---|
| *សមាជិកសហគមន៍វ័យចាស់* | |
| □ យើងមិនផ្តល់គំរូជាវិជ្ជមានទៅដល់សហគមន៍របស់យើងទេ កត្តាដែលរារាងនោះគឺថាយើងតែងតែរកវិធីដ៏ងាយស្រួល ដោយរងចាំមើលរឿងរាវដែលកើតឡើង ហើយបន្ទាប់មកផ្តល់យោបល់ត្រឡប់នៅពេលយើងមិនពេញចិត្តនោះ ។ | □ យើងមានអារម្មណ៍ថាមិនបានទទួលការគាំទ្រពីអ្នកពាក់ព័ន្ធនៅតាមមូលដ្ឋានដើម្បីបង្ហាញពីការបារម្ភ និងតម្រូវការសេវាសង្គមឲ្យបានប្រសើរជាងមុនទេ គឺយើងស្វែងរកការលើកទឹកចិត្តបន្ថែមទៀត។ |
| *យុវជន* | |
| □ យើងមិនយល់បានស៊ីជំរៅទៅលើបញ្ហា និងតម្រូវការដែលពាក់ព័ន្ធនឹងយុវជនកម្ពុជាទេ ។ យើងខ្វះភាពជឿជាក់និងការបញ្ចេញទស្សនៈ ពីព្រោះយើងមិនបានរៀនវិភាគបញ្ហាឲ្យបានស៊ីជុំរៅមែនទែន។ | □ យុវជន និងវ័យកណ្តាលបានជៀសវាងបញ្ហាដូចជា យើងបានគេចវេះពីការពិភាក្សាជាលក្ខណៈបើកចំហរលើបញ្ហាមួយចំនួនដែលយុវជនត្រូវតែដោះស្រាយ (ជាពិសេសប្រសិនបើវាទាក់ទងនឹងគ្រឿងញៀន ឬផ្លូវភេទ) និងការឈឺចាប់ដោយស្ងៀមស្ងាត់។ |
| *សមាជិកសហគមន៍វ័យកណ្តាល* | |
| □ យើងមិនបានរួមចំណែកដល់ការអភិវឌ្ឍឲ្យចេញជាផ្លែផ្កាទេ ពីព្រោះយើងមិនបានយកចិត្តទុកដាក់លើព័ត៌មានអំពីកំណែទម្រង់លិទ្ធិប្រជាធិបតេយ្យ និងដំណើរការអភិវឌ្ឍ។ | □ យើងមានអារម្មណ៍ថារដ្ឋអំណាចមូលដ្ឋាន និងភ្នាក់ងារក្រៅរដ្ឋាភិបាលមិនស្តាប់ការបារម្ភរបស់ពួកយើងអំពីការអភិរក្សព្រៃឈើទេ។ |
| *អង្គការក្រៅរដ្ឋាភិបាល* | |
| □ យើងមិនបានតស៊ូមតិគាំទ្រយ៉ាងសកម្មជាមុនសំរាប់សហគមន៍ទេ យើងត្រូវតែកសាងជំនាញនិងទំនុកចិត្ត។ | □ យើងត្រូវស្វែងរកវិធីគាំទ្រនិងជំរុញឲ្យអភិបាលកិច្ចមូលដ្ឋានបានល្អ។ |

| | |
|---|---|
| *តួអង្គរដ្ឋាភិបាល* | |
| ☐ ស្ត្រីដែលធ្វើការក្នុងជួររដ្ឋាភិបាលខ្វះការឲ្យតម្លៃខ្លួនឯងផ្ទាល់ និងមិនជឿថាពួកគេ អាចរួមចំណែកក្នុងដំណើរការអភិវឌ្ឍបាន។ ឧបសគ្គគឺថាយើងមិនទាន់បានកសាងទំនុកចិត្ត និងសមត្ថភាព។ | ☐ នេះជាពិភពលោករបស់បុរសដែលខ្វះការជឿទុកចិត្តទៅលើសមត្ថភាពរបស់ស្ត្រី គេផ្តល់ឱកាសតិចតួចឲ្យធ្វើការងារល្អៗ និងឲ្យបង្ហាញពីគុណតម្លៃរបស់យើង។ ឧបសគ្គគឺថាយើងមិនទាន់បានធ្វើឲ្យមានឥទ្ធិពលទៅលើបរិយាកាសបែបនេះទេ។ |

## ៥. តើយើងធ្វើការជាមួយគ្នាដោយរបៀបណាដើម្បីជំរុញឲ្យមានសុវត្ថិភាព និងសុខដុមរមនាក្នុងសង្គម?

នៅចុងបញ្ចប់នៃវេទិកាសិក្ខាកាមបានឆ្លើយតបនឹងសំណួរ៖ តើយើងធ្វើការជាមួយគ្នាដោយរបៀបណាដើម្បីដោះស្រាយឧបសគ្គ និងសំរេចបាននូវអ្វីដែលយើងចង់បាន? តើយើងនឹងធ្វើអ្វីអោយខុសប្លែកពីមុន?

លទ្ធផលមានដូចខាងក្រោម៖

| តើខ្ញុំនឹងធ្វើអ្វី? | តើយើងអាចចូលរួមធ្វើអ្វីខ្លះ? |
|---|---|
| *សមាជិកសហគមន៍វ័យចំណាស់* | |
| ☐ យើងត្រូវចូលរួមអោយបានសកម្មដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍសហគមន៍របស់យើង ជាជាងអង្គុយរង់ចាំតវ៉ានៅពេលមានបញ្ហាមកដល់។ | ☐ ក្នុងនាមសមាជិកក្រុមម្នាក់យើងត្រូវតែប្តេជ្ញា សហការជាមួយអ្នកពាក់ព័ន្ធ និងបង្កើតជម្រើសអោយបានច្រើនដើម្បីឆ្លើយតបទៅនឹងតម្រូវការសហគមន៍។ |
| *យុវជន* | |
| ☐ នៅពេលជួបប្រទះនឹងបញ្ហាដែលពាក់ព័ន្ធនឹងយុវជន ដំបូងយើងត្រូវតែសួរ៖ តើខ្ញុំកំពុងធ្វើអ្វីខ្លះក្នុងការរួមចំណែកទៅនឹងបញ្ហានេះ?<br>☐ ហើយយើងម្នាក់ៗតាំងចិត្តនឹងទទួលយកនូវការផ្តល់យោបល់ត្រឡប់ដោយចំហរ។ | ☐ ក្នុងនាមសមាជិកមួយក្រុមយើងខិតខំនាំគ្នាជជែកតាមវិធីងាយៗនៅក្នុងសហគមន៍ ហើយទាញចេញនូវដំណោះស្រាយពីការសន្ទនានេះតាមវិធីឈ្នះឈ្នះ។ |
| *សមាជិកសហគមន៍វ័យកណ្តាល* | |
| ☐ ជាបុគ្គលផ្ទាល់ខ្លួន យើងចូលរួមដោយយកចិត្តទុកដាក់ និងរួមចំណែកស្វែងរកដំណោះស្រាយសំរាប់សហគមន៍របស់យើង។ | ☐ ក្នុងនាមសមាជិកមួយក្រុមយើងប្តេជ្ញាចិត្តស្តាប់គ្នាទៅវិញទៅមក និងកំនត់ពីអ្វីដែលជាតម្រូវការរបស់សហគមន៍។ |
| *ផ្នែកអង្គការក្រៅរដ្ឋាភិបាល* | |
| ☐ យើងទទួលស្គាល់ថា យើងត្រូវឈានមួយជំហានថយក្រោយហើយសួរថា៖ តើយើងកំពុងធ្វើអ្វីដើម្បីអោយអ្វីៗគ្រប់យ៉ាងនៅដដែល? យើងខិតខំធ្វើការឆ្លុះបញ្ចាំងអោយបានច្រើនទៅលើការងារ។ យើងតាំងចិត្តក្នុងការជជែកគ្នាជាមួយអ្នកពាក់ព័ន្ធដើម្បីទទួលយកយោបល់ត្រឡប់។ | ☐ ក្នុងនាមសមាជិកក្រុម យើងតាំងចិត្តនឹងអញ្ជើញអ្នកពាក់ព័ន្ធនានា (អ្នកដែលរងបញ្ហាជាក់លាក់ណាមួយ) មកជជែកគ្នាដើម្បីស្វែងយល់ពីរបៀបដែលអ្នកទាំងអស់គ្នាអាចចូលរួមបាន ដោយយើងមិនត្រូវធ្វើការតែឯងទេ ក្នុងការសំរេចចិត្តក្នុងនាមឲ្យអ្នកដទៃនោះទេ។ |
| *រដ្ឋាភិបាល* | |
| ☐ ក្រុមបានទទួលស្គាល់ថាត្រូវតែតាំងចិត្តធ្វើសកម្មភាពជំនះបញ្ហាយេនឌ័រ។<br>☐ ស្ត្រីតាំងចិត្តបង្កើនជំនាញបន្ថែមដើម្បីអោយខ្លួនមានទំនុកចិត្តក្នុងការចូលរួមវេទិកានានានិងឈប់អោយប្តីនិយាយជំនួសខ្លួន។ | ☐ យើងនឹងលើកទឹកចិត្តអោយកុមាររៀនអោយចប់វិទ្យាល័យ ហើយលើកទឹកចិត្តឪពុកម្តាយបញ្ជូនកូនទៅរៀនឲ្យបានគ្រប់ៗគ្នា។<br>☐ យើងទទួលស្គាល់ថាកម្ពុជាមានច្បាប់ជាច្រើនក៏ប៉ុន្តែច្បាប់ទាំងនោះមិនទាន់អនុវត្តបានពេញលេញនៅឡើយទេ យើងនឹងរួមគ្នាធ្វើការដើម្បីធានាអោយគ្រប់គ្នាអនុវត្តច្បាប់។ |

# លទ្ធផលសង្ខេបរបស់សន្និសីទ









ទស្សនវិស័យនៅឆ្នាំ ២០១៥

ឧបសគ្គខាងក្នុងនិងខាងក្រៅ

តើយើងធ្វើការជាមួយគ្នាដើម្បីដោះស្រាយឧបសគ្គ និង
សម្រេចបាននូវអ្វីដែលយើងចង់បានដោយរបៀបណា?
តើយើងនឹងធ្វើអ្វីខ្លះអោយខុសប្លែកពីមុន?

ការផ្លាស់ប្តូរជាវិជ្ជមាន និងបញ្ហាសំខាន់ៗក្នុងការអភិវឌ្ឍ
ប្រទេសកម្ពុជាក្នុងកំឡុងទសវត្សរ៍ចុងក្រោយ

## តើកន្លងមកយើងបានរៀនសូត្រអ្វីខ្លះ?

សន្និសីទឆ្នាំនេះធ្វើឡើងមានលក្ខណៈខុសប្លែកពីឆ្នាំមុនៗបន្តិច ដោយធ្លាប់តែផ្តោតទៅលើការកំណត់អំពីអ្វីខ្លះដែលអ្នកដទៃត្រូវធ្វើ។ ក៏ប៉ុន្តែនៅឆ្នាំនេះសិក្ខាកាមត្រូវបានសួរអោយពិចារណាពីរបៀបដែលពួកគេរួមចំណែកទៅនឹងបញ្ហានានា និងរក្សាទុកអ្វីៗផ្សេងទៀតនៅដដែល។ យើងមានអារម្មណ៍ថាការធ្វើបែបនេះបាននាំឲ្យសិក្ខាកាមគិតទៅលើគុណភាពនៃលទ្ធផល និងថាយើងអាចធ្វើអោយមានការរីកចំរើន ដោយទាត់ចោលនូវវប្បធម៌ស្តីបន្ទោសដែលមានជាទូទៅនៅក្នុងប្រទេសកម្ពុជា ។

បុគ្គលិករដ្ឋាភិបាលជានារីបានកត់សំគាល់ថា "នេះគឺជាគំនិតរបស់បុរសនៅលើពិភពលោក" ហើយពួកគេបានគិតថាពេលខ្លះយើងមិនអោយតំលៃខ្លួនឯង តែផ្តល់អំណាចទាំងអស់ទៅអោយបុរសវិញ។

*"ពេលខ្លះយើងមានអារម្មណ៍ថាយោបល់របស់យើងមិនមានតម្លៃសោះ ដូច្នេះយើងមិនជឿថាយើងបានរួមចំណែកច្រើននៅក្នុងការប្រជុំអំពីកិច្ចអភិវឌ្ឍន៍ទេ ។ ក៏ប៉ុន្តែក្នុងពេលប្រជុំលើកនេះពួកគេបានស្តាប់នៅពេលដែលខ្ញុំនិយាយ.... យើងត្រូវការបង្កើនសមត្ថភាព និងទំនុកចិត្តថែមទៀត។"*

មនុស្សវ័យចំណាស់ម្នាក់មកពីសហគមន៍បាននិយាយថាៈ

*ជារឿយៗយើងគិតអ្វីងាយៗ... យើងចូលចិត្តអង្គុយរង់ចាំមើលអ្វីដែលកើតឡើងហើយបន្ទាប់មកយើងស្តីបន្ទោសគេនិងរិះគន់លើលទ្ធផល....យើងគួរតែចូលរួមអោយបានសកម្មថែមទៀត។*




សំរាប់ក្រុមយុវជន ពួកគេត្រូវគិតបន្ថែមទៀតអោយបានស៊ីជម្រៅអំពីបញ្ហានា។ យុវវ័យម្នាក់ដែលជាអ្នកស្ម័គ្រចិត្តធ្វើការនៅសហគមន៍បានសំដែងថា៖

*"ខ្ញុំជាអ្នកស្ម័គ្រចិត្តធ្វើការនៅសហគមន៍ម្នាក់ តាមរយៈការចូលរួមក្នុងសន្និសីទនេះខ្ញុំបានយល់រឿងរ៉ាវកាន់តែស៊ីជុំរៅថែមទៀតដែលសហគមន៍កំពុងតែប្រឈមមុខ ហើយខ្ញុំបានគិតរកដំណោះស្រាយជាក់ស្តែង និងសារៈប្រយោជន៍សំរាប់សហគមន៍ខ្ញុំ។ ជាពិសេសដំណើរការសន្និសីទបានជួយខ្ញុំអោយគិតកាន់តែស៊ីជម្រៅថែមទៀត តាមរយៈនេះពិតជាជុំរុញអោយខ្ញុំខិតខំ....វាជួយអោយខ្ញុំគិតបន្ថែមមួយកំរិតទៀត ហើយវាមិនមែនជារឿងងាយស្រួលទេសំរាប់ខ្ញុំ។ នៅចុងបញ្ចប់នៃសន្និសីទនេះខ្ញុំបានដឹងថាវាជាជំនាញសំខាន់មួយសំរាប់អភិវឌ្ឍន៍ជីវិតខ្ញុំ។"*

ថ្វីបើដំណើរការពិភាក្សាបានបង្ហាញថាមិនមានកិច្ចសហការណ៍គ្នា ប៉ុន្តែទាំងបុគ្គលិករដ្ឋាភិបាលនិងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលសុទ្ធតែបានផ្តល់យោបល់ពីបំណងចង់ឲ្យមានការចែករំលែក និងឲ្យមានកិច្ចសហការគ្នាកើតមានឡើង ។

*"ខ្ញុំបានទាញចេញនូវការរៀនសូត្រមួយថា នៅពេលដែលជួបនឹងបញ្ហា ខ្ញុំគួរតែឈានមួយជំហានថយក្រោយ ហើយយកបញ្ហាដែលបានជួបនោះដាក់លើតុដើម្បីពិភាក្សាទទួលចំលើយតបពីអ្នករួមការងារ បន្ទាប់មកធ្វើការជ្រើសរើសដើម្បីយកទៅអនុវត្ត។" (បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលជាស្ត្រី)។*

*"ខ្ញុំចង់ឲ្យអ្នកពាក់ព័ន្ធដទៃទៀត ដូចជាអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការពាក់ព័ន្ធពីរឿងស្ត្រី និងកុមារ....ពីព្រោះខ្ញុំនឹងទទួលបានគំនិតផ្សេងគ្នាពីការសហការណ៍គ្នា" (ស្ត្រីមកពីមន្ទីរកិច្ចការនារីខេត្ត)។*

យើងចាប់អារម្មណ៍ទៅលើទស្សនវិស័យរបស់ក្រុមផ្សេងៗគ្នា និងវិធីបង្ហាញពីសារៈសំខាន់នៃសេដ្ឋកិច្ច និងកត្តាសង្គមក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។ ពួកគេបានបង្ហាញអោយឃើញពីភាពមានការងារ ការរកប្រាក់ចំណូល និងសុវត្ថិភាពស្បៀងគ្រប់គ្រាន់។

ការជជែកគ្នាពីការគ្រប់គ្រងធនធានធម្មជាតិ អភិបាលកិច្ច និងការធានាអោយមានសេវាសង្គម ទាំងពីរនេះមានការទទួលខុសត្រូវ និងឆ្លើយតបទៅនឹងតម្រូវការសហគមន៍។ ហេតុដូច្នេះពួកគេបានទទួលស្គាល់ផងដែរថាសហគមន៍ និងអង្គការសង្គមស៊ីវិលត្រូវតែរួមចំណែកយ៉ាងសកម្ម ជាជាងរង់ចាំអ្នកដទៃមកធ្វើអោយ។

ក៏ប៉ុន្តែពួកគេក៏បានកំណត់នូវគុណតម្លៃដែលផ្សាភ្ជាប់សង្គមកម្ពុជាទាំងមូលដូចជាការងាកទៅរកវប្បធម៌នៃការចែករំលែក និងធ្វើការរួមគ្នា ដូចជាការគោរពទស្សនៈគ្នាទៅវិញទៅមក ស្មោះត្រង់នឹងគ្នា និងការប៉ងប្រាថ្នាចង់បានសុខដុមរមនាក្នុងសង្គម ។នៅពេលដែលយើងឈានថយក្រោយមួយជំហាន យើងបានឃើញថាក្រុមបានកំណត់នូវសុខមាលភាពដូចខាងក្រោម៖

- បំណងប្រាថ្នាសំរាប់សុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួន
- សំភារៈដែលជួយឲ្យជីវិតរស់នៅបានស្រួល និងសុខភាពល្អ (ការចិញ្ចឹមជីវិត ស្បៀងអាហារ និងជំរក ព្រមទាំងលទ្ធភាពទទួលសេវាកម្ម)
- ការទំនាក់ទំនងល្អក្នុងសង្គម (ការផ្សាភ្ជាប់ទំនាក់ទំនងសង្គម ការគោរពគ្នាទៅវិញទៅមក និងលទ្ធភាពជួយគ្នា)

នៅក្នុងសុន្ទរកថារបស់ឯកឧត្តម **ស៊ុន សុខន** បានសរសើរពីលទ្ធផលសំរេចបាន និងរឿងជាក់ស្តែងដែលសិក្ខាកាមបានពិភាក្សាដោយផ្តោតលើបញ្ហាខាងក្នុងជាជាងស្តីបន្ទោសអ្នកដទៃ។ ឯកឧត្តមក៏បានគូសបញ្ជាក់ផងដែរថា បញ្ហាតែងតែកើតឡើង ដោយសមាជិកសហគមន៍ អង្គការក្រៅរដ្ឋាភិបាល និងរដ្ឋាភិបាលមិនស្តាប់គ្នាទៅវិញទៅមកបានល្អ ។

## សេចក្តីសន្និដ្ឋាន

ក្រុមអ្នកសម្របសម្រួល *វីប៊ីអិនខេ* មានមោទនៈភាពបំផុតចំពោះការចូលរួមរបស់សិក្ខាកាមទាំង ៩១នាក់ ប្រកបដោយថាមពល និងមានភាពរីករាយ។ យើងទទួលស្គាល់ថាវិធីសាស្រ្តដែលយើងប្រើប្រាស់នៅក្នុងសន្និសីទសហគមន៍ធ្វើឲ្យមានការប្រឈមសំរាប់អ្នកមួយចំនួន ដែលតម្រូវអោយសិក្ខាកាមបោះបង់ចោលទំលាប់ចាស់នោះ ដូចជាការប្រឈមនឹងការរំពឹងទុកទៅលើអ្វីដែលសិក្ខាសាលាមាន។ វាជាសញ្ញាណដែលតែងតែយល់ថាអ្នកសម្របសម្រួលមានចម្លើយ ឬផ្តល់ចម្លើយ។ ជំនួសការផ្តល់ចម្លើយនេះ យើងបានសួរសិក្ខាកាមនូវសំណួរ ហេតុអ្វី? និង ហើយបើដូចនេះ? ។ យើងសួរពួកគេឲ្យជ្រើសរើសអាទិភាពចំនួន ២ ឬ៣ ពីចំលើយជាច្រើនដែលពួកគេរកឃើញ។ ពីដំបូងនៅពេលដែលយើងនិយាយពីការរំពឹងទុក អ្នកទាំងអស់គ្នាខំប្រឹងស្តាប់គ្នាទៅវិញទៅមក។ ពេលខ្លះ គេត្រឡប់ជាមិនបានស្តាប់គ្នា ដូចជាការជជែកវែកញែករវាងស្ត្រីវ័យក្មេង និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលវ័យចំណាស់។ អ្នកសម្របសម្រួលបានលើកឡើងនូវអ្វីដែលបានកើតឡើង និងរំលឹកពីរបៀបស្តាប់គ្នាឡើងវិញក្នុងអង្គសន្និសីទ។ ការអនុវត្តជាសាធារណៈបែបនេះមិនមែនជាការងាយស្រួលនោះទេ ព្រោះសិក្ខាកាមមួយចំនួនមានអារម្មណ៍មិនសូវស្រួលក្នុងចិត្ត។ ក៏ប៉ុន្តែនៅចុងបញ្ចប់សិក្ខាសាលាមានសភាពស្រួលបួលវិញ ហើយសិក្ខាកាមចេះវែកញែកអ្វី ជាឧបសគ្គខាងក្នុង (អ្វីដែលជារបស់ខ្លួនផ្ទាល់) និងអ្វីជាឧបសគ្គខាងក្រៅ។ យោបល់ត្រឡប់នៅចុងបញ្ចប់នៃការពិភាក្សាក្រុមធំ និងការវាយតម្លៃរបស់សិក្ខាកាមគឺមានលក្ខណៈវិជ្ជមាន ទៅលើរបៀបសន្ទនាសហគមន៍ដែលបានឲ្យសិក្ខាកាមធ្វើការរួមគ្នា ថ្វីបើនៅមានអ្នកខ្លះមិនបានបង្ហាញចំនុចវិជ្ជមាននៅពេលចាប់ផ្តើមយ៉ាងណាក៏ដោយ។

> *"ដំបូងនៅពេលខ្ញុំចូលមកដល់សាលសន្និសីទ ខ្ញុំគិតថាខ្លួនខ្ញុំមានចំណេះដឹងទាបបើប្រៀបធៀបជាមួយមនុស្សមកពីអង្គការក្រៅរដ្ឋាភិបាល និងមកពីរដ្ឋាភិបាល។ តាមពិតដំណើរការសន្និសីទបានលើកទឹកចិត្តខ្ញុំឲ្យនិយាយចេញពីបេះដូងអំពីអ្វីដែលខ្ញុំចង់និយាយ។ ខ្ញុំមានអារម្មណ៍សប្បាយរីករាយ ហើយចង់ឲ្យសមាជិកក្រុមប្រឹក្សានៅក្នុងឃុំរបស់ខ្ញុំចូលរួមក្នុងសន្និសីទនៅឆ្នាំក្រោយ។" (ស្ត្រីវ័យកណ្តាលមកពីខេត្តកណ្តាល)*

**ខែ កក្កដា ឆ្នាំ ២០១០**